# មេរៀនទី ១៤៨៖ ព្រះត្រាស់ហៅអេសាយ

## អេសាយ ៦៖១-៨

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/oleFGvR8y2k

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/LQWHuOXIRZs

**គោលបំណង៖ ព្រះទ្រង់បរិសុទ្ធ។**

**ខគម្ពីរចងចាំ៖ ១ ពេត្រុស ១៖១៦** *"ដ្បិតមានសេចក្តីចែងទុកមកថា «ចូរឲ្យឯងរាល់គ្នាបានបរិសុទ្ធ ដ្បិតអញជាបរិសុទ្ធ»។"*

**ចំរៀង** ( *យូធូបលីង* )៖

១.ខ្ញុំដើរតាមព្រះយេស៊ូវ https://youtu.be/aasilZXGorc

២.ខ្ញុំបានសម្រេចចិត្ត https://youtu.be/MR1Yv--Q4oo

៣.ព្រះបន្ទូលជាចង្កៀង https://youtu.be/fOSOZBVSb0Y

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត "ទឹកដីបរិសុទ្ធ"**




សំភារៈដែលត្រូវការ៖ ក្រមា

១. ចែកកុមារជា ២ ក្រុម រួចឱ្យពួកគេឈរជាពីរជួរ

២. លាតក្រមានៅចំកណ្តាលថ្នាក់រៀន រួចពន្យល់កុមារថា ក្រមាគឺសំដៅទៅលើទីកន្លែងដ៏បរិសុទ្ធរបស់ព្រះ

៣. ចាប់ផ្តើមលេង ដោយឱ្យកុមារម្នាក់ៗត្រូវរត់ទៅកាន់ចុងម្ខាង នៃថ្នាក់រៀន ហើយត្រលប់មកវិញ ប៉ុន្តែ ពេលដែលពួកគេរត់មក ដល់ក្រមាឱ្យពួកគេលុតជង្គង់ចុះ នៅមុខក្រមានោះ ( ពួកគេមិនអាចប៉ះក្រមាបានទេ ពីព្រោះជាទីកន្លែងបរិសុទ្ធ ) ហើយអធិស្ឋានថា (អរព្រះគុណព្រះអង្គ) រួចឱ្យពួកគេបន្តរត់ ទៅកាន់ជួររបស់ពួកគេវិញ។ ប្រសិនបើគេប៉ះក្រមាគេចាញ់ល្បែងនេះ



៤. ក្រុមណាដែលមានសមាជិកក្រុមរត់គ្រប់គ្នាបានលឿនជាងគេ ក្រុមនោះនឹងឈ្នះល្បែងនេះ

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា អ្វីដែលបរិសុទ្ធគឺយើងត្រូវប្រព្រឹត្តចំពោះគេឱ្យខុសពីគេ ថ្ងៃនេះយើងនឹងរៀនអំពីព្រះជាម្ចាស់ទ្រង់បរិសុទ្ធ។

**៤. ការណែនាំមេរៀន**

ព្រះទ្រង់ខ្ពង់ខ្ពស់ជាងយើងពីព្រោះទ្រង់បរិសុទ្ធ ព្រះទ្រង់ល្អឥតខ្ចោះ។ ភាពបរិសុទ្ធមានអត្ថន័យច្រើនយ៉ាង ហើយនៅថ្ងៃនេះយើងនឹងស្វែងយល់ពីអត្ថន័យដែលយើងនិយាយថាព្រះបរិសុទ្ធ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

រឿងនៅក្នុងព្រះគម្ពីរថ្ងៃនេះ គឺនិយាយពីព្រះត្រាស់ហៅអេសាយឱ្យធ្វើការងារឱ្យទ្រង់ដោយធ្វើជាហោរាសម្រាប់សាសន៍យូដា។ នៅពេលដែលព្រះត្រាស់ហៅអេសាយ ទ្រង់បានប្រទានឱ្យអេសាយនូវនិមិត្តពីខ្លួនគាត់។ អេសាយបានឃើញព្រះអម្ចាស់ទ្រង់គង់លើបល្ល័ង្កនៅទីខ្ពស់ ហើយបានដំកើងឡើង ឯរំភាយព្រះពស្ត្រទ្រង់សាយមកពេញក្នុងព្រះវិហារ!

នៅក្នុងព្រះវិហារ អេសាយក៏បានឃើញទេវតាពិសេសដែលហៅថាសេរភីម។ សេរភីមទាំងនោះមានស្លាប ៦ ក៏បាំងមុខដោយស្លាប២ បាំងជើងដោយស្លាប២ ហើយប្រើ២សំរាប់ហើរ។ អេសាយក៏បានធុំក្លិនផ្សែងនៅពេញក្នុងព្រះវិហារផងដែរ។ ហើយអេសាយបានឮសេរភីមបន្លឺឡើងថា “បរិសុទ្ធ បរិសុទ្ធ ព្រះអង្គទ្រង់បរិសុទ្ធ”។ គាត់ក៏បាននិយាយដែរថាសម្លេងរបស់សេរភីមគឺដូចជាសម្លេងផ្គរលាន់! សម្លេងរបស់ពួកគេឮខ្លាំងរហូតដល់ក្របទ្វារក៏ញ័រដែរ។

នៅពេលដែលអេសាយបានឃើញព្រះអង្គនៅក្នុងព្រះវិហារ គាត់ដឹងថាទ្រង់ពិតជាអស្ចារ្យ និងបរិសុទ្ធយ៉ាងណា! គាត់ក៏បានឃើញគាត់មានភាពខុសពីព្រះយ៉ាងណាផងដែរ។ គាត់ដឹងថាគាត់បានប្រព្រឹត្ត អំពើបាបជាច្រើនដែលធ្វើឱ្យព្រះមិនសប្បាយព្រះទ័យ។ មានសេរភីមមួយបានហើរទៅកាន់អសនាក្នុងព្រះវិ-ហារ ហើយយកដង្កៀបមកកៀបរងើកភ្លើងហើយយកទៅហើរទៅប៉ះនឹងមាត់របស់អេសាយ ក៏បានធ្វើឱ្យគាត់បានស្អាត (ក្លាយជាមនុស្សសុចរិត)។

រួចព្រះអង្គក៏មានបន្ទូលថា “តើអញនឹងចាត់អ្នកណាឲ្យទៅ តើអ្នកណានឹងទៅឲ្យអញ?” នោះអេសាយក៏ឆ្លើយឡើងថា “ទូលបង្គំនៅឯណេះហើយ សូមចាត់ទូលបង្គំចុះ!” អេសាយចង់ជួយបម្រើដល់ព្រះដ៏អស្ចារ្យ និង បរិសុទ្ធនេះ។

បរិសុទ្ធគឺមានន័យថាញែកដាច់ដោយឡែកសម្រាប់ការប្រព្រឹត្ត ឬប្រើប្រាស់យ៉ាងពិសេស។ យើងចូលទៅចំពោះព្រះដ៏បរិសុទ្ធខុសពីការដែលយើងចូលទៅជិតមិត្តភក្តិរបស់យើង។ ព្រះជាម្ចាស់គឺត្រូវញែកជាពិសេស គឺខុសគ្នាសូម្បីតែមនុស្សដែលជាទីគោរពបំផុតក៏ដោយ។ ព្រះទ្រង់បរិសុទ្ធ ពីព្រោះទ្រង់គឺល្អឥតខ្ចោះហើយទ្រង់គ្មានបាបនោះទេ។ មិនតែប៉ុណ្ណោះ ព្រះដ៏បរិសុទ្ធនេះទ្រង់ស្រឡាញ់យើង ហើយទ្រង់ចង់ឱ្យយើងក្លាយជាមិត្តរបស់ទ្រង់ ហើយទ្រង់ក៏អញ្ជើញយើងឱ្យចូលទៅចំពោះទ្រង់ និងស្រឡាញ់ទ្រង់គ្រប់ពេលវេលាផងដែរ!

ព្រះអង្គចង់ឱ្យយើងបានបរិសុទ្ធដូចជាទ្រង់ដែរ។ នេះគឺមានន័យថាយើងត្រូវប្រព្រឹត្តខ្លួនឱ្យខុសពីលោកិយនេះ ត្រូវធ្វើខ្លួនជាមនុស្សពិសេសឱ្យស័ក្តិសមទៅនឹងមនុស្សដែលនៅក្នុងនគររបស់ព្រះ។ ព្រះដ៏បរិសុទ្ធរបស់យើងចង់ឱ្យយើងបរិសុទ្ធ ដូច្នេះហើយទើបទ្រង់ធ្វើការនៅក្នុងជីវិតរបស់យើងដើម្បី ផ្លាស់ប្តូរនូវអ្វីដែលមិនសព្វព្រះហឫទ័យចេញ។ ព្រះជួយយើងឱ្យក្លាយជាមនុស្សបរិសុទ្ធបាន ពីព្រោះ ទ្រង់គឺជាព្រះដែលបរិសុទ្ធ។ ហើយយើងទទួលបាននូវអភ័យឯកសិទ្ធិដើម្បីបម្រើព្រះជាម្ចាស់ដូចជា អេសាយដូច្នោះដែរ។ សូមឱ្យយើងរាល់គ្នាបានបរិសុទ្ធ ពីព្រោះព្រះអង្គទ្រង់បរិសុទ្ធ ហើយសូមឱ្យយើងបាន មានបន្ទូលទៅកាន់ទ្រង់ថា “ទូលបង្គំនៅឯណេះហើយ សូមចាត់ទូលបង្គំចុះ!”

## ៦. សំនួរពិភាក្សា

១. តើពួកទេវតានៅក្នុងព្រះវិហារនៃព្រះបាននិយាយអ្វី? (*បរិសុទ្ធ បរិសុទ្ធ ព្រះអង្គទ្រង់ បរិសុទ្ធ*)

២. តើបរិសុទ្ធមានន័យយ៉ាងដូចម្តេច? (*មិនដើរតាមលោកិយ, ល្អឥតខ្ចោះ, ស្អាតនិងមិនមានបាប*)

៣. តើយើងអាចក្លាយជាបរិសុទ្ធបានដោយរបៀបណា? *(មិនធ្វើអ្វីដែលលោកិយធ្វើ, ជាមនុស្សពិសេសសម្រាប់នគរព្រះ, ប្តូរការប្រព្រឹត្តទាំងឡាយណាដែលព្រះមិនសព្វព្រះហឫទ័យ)*
៤. ហេតុអ្វីបានជាយើងត្រូវបរិសុទ្ធ? *(ពីព្រោះព្រះទ្រង់បរិសុទ្ធ)*

**៧. ល្បែងកំសាន្ត** «ទះដៃ»



១. ឲ្យកុមារឈរទាំងអស់គ្នា

២. នៅពេលដែលគ្រូដាក់ដៃទាំងពីរទៅមុខស្មើគ្នា កុមារទាំងអស់មិនត្រូវទះដៃនោះទេ

៣. ប៉ុន្តែនៅពេលដែលគ្រូ លើកដៃណាមួយខ្ពស់ជាងគ្នា នោះកុមារត្រូវទះដៃ



៤. ប្រសិនបើកុមារមិនអាចធ្វើតាមការណែនាំរបស់គ្រូ ៣ដង នោះគេចាញ់ល្បែងនេះ ហើយត្រូវអង្គុយចុះ។

៥. លេងល្បែងនេះរហូតដល់នៅសល់កុមារតែម្នាក់ជាអ្នកឈ្នះ។

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ពួកគេត្រូវតែយកចិត្តទុកដាក់ចំពោះការណែនាំរបស់គ្រូក្នុងការលេងល្បែងនេះ ក៏ដូចគ្នានេះដែរ យើងត្រូវតែយកចិត្តទុកដាក់ សម្លឹងមើលទៅព្រះដើម្បីឲ្យយើងអាចបរិសុទ្ធបាន។

**៨. ខគម្ពីរចងចាំ**

**១ ពេត្រុស ១៖១៦** *"ដ្បិតមានសេចក្ដីចែងទុកមកថា «ចូរឲ្យឯងរាល់គ្នាបានបរិសុទ្ធ ដ្បិតអញជាបរិសុទ្ធ»"*

**៩. ហត្ថកម្ម "សូមចាត់ខ្ញុំ"**

សំភារៈដែលត្រូវការ៖ បោះពុម្ពក្រដាសហត្ថកម្ម, ក្ងួល័រ




១. សូមបោះពុម្ពក្រដាសហត្ថកម្មចែកឱ្យកុមារម្នាក់មួយសន្លឹក

២. ឱ្យកុមារគូសផ្ទាន់ដៃរបស់ពួកគេនៅលើក្រដាសហត្ថកម្ម និងផាត់ពណ៌រូបទាំងអស់

៣. គ្រូសួរកុមារថា "តើអ្នកណាអាចទៅបម្រើព្រះជាម្ចាស់បាន? តើអ្នកណាដែលព្រះអាចប្រើបាន?" ហើយឱ្យកុមារឆ្លើយថា "ទូលបង្គំនៅទីនេះហើយ សូមចាត់ទូលបង្គំចុះ!"

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ភាពបរិសុទ្ធរបស់ព្រះអាចផ្លាស់ប្តូរជីវិតរបស់យើង តាមរយៈការមានទំនាក់ទំនងជាមួយនឹងព្រះយេស៊ូវ។ តើព្រះបានបង្ហាញភាពបរិសុទ្ធរបស់ទ្រង់មកអ្នកបានយ៉ាងដូចម្ដេច? សូមចំណាយពេលវេលា ក្នុងការគិតពីចំណុចនេះ។ យើងអាចមើលឃើញភាពបរិសុទ្ធរបស់ព្រះតាមរយៈការជាច្រើន... ដូចជាតាមរយៈភាពស្រស់ស្អាតនៃធម្មជាតិ ឬក៏តាមរយៈបទពិសោធន៍នៃការអធិស្ឋានដ៏អស្ចារ្យ។ នៅពេលដែលអ្នកទទួលបានបទពិសោធន៍នេះនៅពេលក្រោយ សូមទទួលយកដោយអរព្រះគុណទ្រង់អស់ពីចិត្ត។

# “ សូមចាត់ខ្ញុំ ”

“តើអញនឹងចាត់អ្នកណាឲ្យទៅ? តើអ្នកណានឹងទៅឲ្យអញ?” អេសាយ ៦:៨



“ទូលបង្គំនៅទីនេះហើយ សូមចាត់ទូលបង្គំចុះ!” អេសាយ ៦:៨

គូសរូបដៃរបស់អ្នកនៅទីនេះ